# ឱផ្ទៃស្រុកខ្មែរ



ចម្រៀងសំរាប់កុមារមត្តេយ្យ ភាគ២

©រចនារូបភាពដោយ មីតា រ៉េកូ (MITA Reiko) (©រក្សាសិទ្ធិគ្រប់យ៉ាង)　絵：三田 玲子
©Illustrated by MITA Reiko

បោះពុម្ពលើកទី១ ឆ្នាំ១៩៩៨ នៅភ្នំពេញ (1st edition, 1998)
បោះពុម្ពលើកទី២ ឆ្នាំ១៩៩៩ នៅភ្នំពេញ (2nd edition, 1999)
បោះពុម្ពលើកទី៣ ឆ្នាំ២០០៣ នៅភ្នំពេញ (3rd edition, 2003)
បោះពុម្ពលើកទី៤ ឆ្នាំ២០០៥ នៅភ្នំពេញ (4th edition, 2005)
បោះពុម្ពលើកទី៥ ឆ្នាំ២០០៦ នៅភ្នំពេញ (5th edition, 2006)

បោះពុម្ពលើកទី៦ដោយ : អង្គការគាំពារកុមារខ្មែរ(CYK)
នៅភ្នំពេញ ខែកក្កដា ឆ្នាំ២០១០

មូលនិធិ : Lisa Ono Soroptimist International of Tokyo, Azabu

ចំនួន : ៣០០ក្បាល

លេខ : CYK N10020

រោងពុម្ព : JSRC Printing House

発行：特定非営利活動法人　幼い難民を考える会
2010年7月（6刷）プノンペン

協力：小野リサ　国際ソロプチミスト 東京ー麻布

部数：300冊

番号：CYK N10020

印刷所：JSRC Printing House

ហាមចំលងផ្នែកណាមួយនៃសៀវភៅនេះ ជាប្រយោជន៏ផ្ទាល់ខ្លួន ឬលក់ដូរដោយគ្មានការអនុញ្ញាតិពីអង្គការគាំពារកុមារខ្មែរ
No part of this book should be copied for commercial use without a permission of Caring for Young Khmer

# មាតិការឿង


មាន់ខ្លួត!........................................................................១

ចាក់ខាត់ណា..................................................................៣

លើកដៃឡើងរាំ................................................................៥

គន់មើលកង្ហាររគ្រូវខ្យល់.......................................................៥

វិន័យដែលអ្នកគ្រូផ្តាំ.............................................................៧

ដើរ ឬ ដេក.....................................................................៩

កន្តុបម៉ែមួយ...................................................................១១

សារិកាកែវអើយ..............................................................១៣

កូនក្រសារតូចៗ................................................................១៥

តាក់ទឹងក្តឹងៗ....................................................................១៧

កុមារស្រុកស្រែ.................................................................១៩

ឱផ្ទៃស្រុកខ្មែរ.................................................................២១

ទីមួយខែមករា.................................................................២៣

# មាន់ខ្គត!

តុក ក តត! តុក ក តត!

តុក ក តត! ឆ្លេឆ្លារកពង

តុក ក តត! តុក ក តត!

តុក ក តត! មុខឡើងក្រហម

ក្នុងមួយថ្ងៃពងមួយ ជាជំនួយជួយផ្ដល់អាហារ

បើមិនថែរក្សា មានថ្ងៃណាមាន់មិនពងឡើយ ៕

(ច្រៀង២ដង)



# ចាក់ខាត់ណា

ចាក់ ខាត់ ណា កូឡាជូនឡៀវ

អុក សៀវ មៀវ កូលីតបាយ សងៗៗៗ ៕



# លើកដៃឡើងរាំ

លើកដៃឡើងរាំ សមអើយសែនសមពាក់នាឡិកា
ពាក់អាវបៅងស្នា សក់អ៊ុតស្តៃក្តោប
លាបថ្នាល់ក្រហម មកលេងរាំវង់ ។ (ច្រៀង២ដង)

# គន់មើលកង្ហារត្រូវខ្យល់

គន់មើលកង្ហារត្រូវខ្យល់ ផាយផាត់មកដល់ត្រជាក់កាយា
ទោរទន់ព្រះសុរិយាៗ ព្រលប់កាលណា យើងនាំគ្នារាំ
យើងរាំៗ យើង យើងរាំៗៗៗៗ ។ (ច្រៀង២ដង)



# វិន័យដែលអ្នកគ្រូផ្តាំ

វិន័យដែលអ្នកគ្រូផ្តាំទៅ

ថាឱ្យពាលពៅជំរាបសួរចាស់ៗ

ហេតុអ្វីបានជាពៅមិនចាំច្បាស់ (២ដង)

ភ្លេចទាំងសំពះ ភ្លេចទាំងថាអរគុណ

ក្រោយៗ សំពះចាស់ៗ មុន (២ដង)

រួចថាអរគុណ មុនទទួលអ្វីៗ

ស្តាយណាស់ អ្នកគ្រូខានចែកចំណី (២ដង)

ព្រោះតែថ្លាថ្លៃភ្លេចវិន័យអ្នកគ្រូ (២ដង) ៕



# ដើរ ឬ ដេក

ដើរឬដេកដងខ្លួនឱ្យត្រង់ ត្រូវតំរង់ទាន់ខ្លួននៅក្មេង
ទោះអង្គុយឬមួយឈរលេង
យើងក្មេងៗ ឈរឱ្យត្រង់ខ្លួន ។

មុខញញឹមសង្ឃឹមជានិច្ច កុំបែរគេចមូរមុខបិទមាត់
ហ៊ានសួរហ៊ានឆ្លើយឱ្យចេះចាំស្ទាត់
ជាពលរដ្ឋប្រសើរថ្ងៃក្រោយ ៕



# កន្ទុបម៉ែមួយ

### បទទី១

កន្ទុបៗ ម៉ែមួយ ម៉ែឱ្យៗ ចាំផ្ទះ (២ដង)
រវល់ៗទៅណា អឺៗៗ អឺយ ឱ្យទាស៊ីស្រូវ (២ដង) ។
រំពាត់ៗម៉ែមួយ ម៉ែវាយៗឥឡូវ (២ដង)
ឱ្យទាៗស៊ីស្រូវ អឺៗៗ អឺយ រវល់ទៅណា (២ដង) ៕

### បទទី២

កន្ទុបៗម៉ែមួយ ម៉ែឱ្យៗចាំចាប (២ដង)
រវល់ៗទៅណា អឺៗៗ អឺយ ឱ្យចាបស៊ីស្រូវ (២ដង) ។
សូមម៉ែមេត្តាតុប ព្រោះតុបនាងនៅក្មេងខ្ចី (២ដង)
មិនទាន់ៗដឹងក្តី អឺៗៗ អឺយ សូមប្រណីម្តង (២ដង) ៕

### បទទី៣

កន្ទុបៗម៉ែមួយ ម៉ែឱ្យៗចាំចាប (២ដង)
រវល់តែអង្គុយស្ងាប អឺៗៗ អឺយ ឱ្យចាបស៊ីស្រូវ (២ដង) ។
ថ្ងៃក្រោយៗកុំភ្លេច ពេលម៉ែៗមិននៅ (២ដង)
ជួយមើលៗខុសត្រូវ អឺៗៗ អឺយ ជំនួសម៉ែផង (២ដង) ៕



# សារិកាកែវអើយ

សារិកាកែវអើយ អ្នកហើរទៅណា

អ្នកហើរជិតៗ អ្នកកុំហើរឆ្ងាយ

ហើរមក ហើរមក ហើរមក

ហើរឆ្ងាយ ប្រយ័ត្ន គេចាប់ សូមអញ្ជើញប្រញាប់

ហើរមកលឿនៗ ៕

(ច្រៀង២ដង)



# កូនក្រសារតូចៗ

ក្រសារតូចៗ វាទុំលើមែកឈើ
កូនទៅបាត់ម៉ែមិនដឹងកូនទៅណា
ពេលទៅកូនប្រាប់ ពេលមកកូនជំរាប
មាត់កូនញញឹមម៉ែស្រឡាញ់កូនទេ (២ដង) ៕
(ច្រៀង២ដង)



# តាក់ទីងក្អឹងៗ

តាក់ ទីង ក្អឹងៗ

បងមុជទឹកបឹងចាប់បានត្រី៥

អា២ធ្វើផ្អក អា៣ធ្វើម៉ាំ

ចាប់បានត្រី៥ ទុកបរិភោគណា៎ (២ដង) ។

(ច្រៀង២ដង)

តាក់ ទីង ក្អឹងៗ

